**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការក្រុងព្រះសីហនុ
<u>សំណុំរឿងព្រហ្មទណ្ឌ</u>
លេខ ៣៣៩ ចុះថ្ងៃទី ២៨
ខែ ធ្នូ ឆ្នាំ ២០០២
<u>សាលក្រម</u>
លេខ ៥០ ចុះថ្ងៃទី ៣០
ខែ មិថុនា ឆ្នាំ ២០០៤

សាលក្រមនេះចូលជាស្ថាពរចំពោះឈ្មោះ **យ សយ** តែមិនទាន់ចូលជាស្ថាពរ
ចំពោះជនជាប់ចោទឈ្មោះ **ន ហ** ហៅប្តីយាយ **អម** ។
ក្រុងព្រះសីហនុ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៥
**ក្រឡាបញ្ជី**
[redacted]

**គាននាមប្រជារាស្ត្រខ្មែរ**
**តុលាការក្រុងព្រះសីហនុ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ បានបើកសវនាការជាសាធារណៈនៅតុលាការក្រុងព្រះសីហនុ នាថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៤ ដោយមានសមាសភាពដូចតទៅ :

**<u>ចៅក្រមជំនុំជំរះ</u>**

លោក [redacted] អនុប្រធានតុលាការក្រុងព្រះសីហនុ

**<u>តំណាងអយ្យការ</u>**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការក្រុងព្រះសីហនុ

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted] ជាក្រឡាបញ្ជី

ដើម្បីជំនុំជំរះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៣៩ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២ ដែលមានជនល្មើស :

១-ឈ្មោះ **ន ហ** ហៅ ប្តីយាយ **អម** ភេទប្រុស អាយុ ៣២ឆ្នាំ ជាតិខ្មែរ កើតនៅភូមិព្រែកកល់ ឃុំល្វេ ស្រុកកោះសូទិន ខេត្តកំពង់ចាម មានទីលំនៅនៅក្រុម ១១ ភូមិ ២ សង្កាត់ ២ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ប្រពន្ធឈ្មោះយាយ **អម** ឪពុកឈ្មោះ **ន ហ** ម្តាយឈ្មោះ **យ ឈ** ( គេចខ្លួន ) ។

២-ឈ្មោះ **យ សយ** ភេទប្រុស អាយុ ៣០ឆ្នាំ ជាតិខ្មែរ កើតនៅភូមិតាប៉ាង ឃុំមរាម ស្រុករមាសហែក ខេត្តស្វាយរៀង សាសនាព្រះពុទ្ធ មានទីលំនៅនៅក្រុម ១១ ភូមិ ៣ សង្កាត់ ២ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ របររកស៊ីរត់តាក់ស៊ី ប្រពន្ធឈ្មោះ **ត ចន** មានកូន ០៤នាក់ ឪពុកឈ្មោះ **ភ ម** ( ស ) ម្តាយឈ្មោះ **ម រ** ( រ ) ទោសពីមុន *<u>គ្មាន</u>* ( នៅក្រៅឃុំ ) ។

-ត្រូវចោទពីបទ<u>បង្ករបួសដោយចេតនា</u> ប្រព្រឹត្តនៅភូមិ ៣ សង្កាត់ ២ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៤៤៦ ឧព.២០០៣ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៣ របស់ព្រះរាជអាជ្ញាអមតុលាការក្រុងព្រះសីហនុ ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ១៣០៨ តព ២០០៣ ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០០៣ របស់ចៅក្រមស៊ើបអង្កេតនៃតុលាការក្រុងព្រះសីហនុ ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ ១៣១៧ តព.០៣ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៣ របស់ប្រធានតុលាការក្រុងព្រះសីហនុ ។

## ដំណើររឿងហេតុមានដូចខាងក្រោមនេះ :

-កាលពីយប់ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០២ វេលាម៉ោង ៨:០០ជាង ឈ្មោះ គ ត អង្គុយមើលទូរទស្សន៍នៅផ្ទះ ពេលកំពុងតែមើលនោះស្រាប់តែភ្លើងអគ្គិសនីដាច់ គ ត ចេញមកក្រៅផ្ទះ ឃើញផ្ទះរបស់គេជិតខាងភ្លើងអគ្គិសនីឆេះគ្រប់១ផ្ទះ ឈ្មោះ គ ត បានកាន់កូនឈើមួយដើរមកកន្លែងកាប៊ិនភ្លើង ដើម្បីពិនិត្យមើលក្រែងឌីស្យុងទ័រលោត ពេលទៅមើលឃើញឌីស្យុងទ័រលោតមែន ឈ្មោះ គ ត បានយកកូនឈើផ្ដិះឌីស្យុងទ័រ ស្រាប់តែឈ្មោះ ន ច ហៅប្ដីយាយ អម ហូតខ្សែក្រវាត់ពីចង្កេះមកវាយលើឈ្មោះ គ ត ខាងក្បាលខ្សែក្រវាត់ត្រូវដងខ្លួន និង ក្បាលជាច្រើនខ្សែក្រវាត់មិនបណ្ដាលបែកក្បាលទេ ពេលនោះ គ ត បានស្ទុះរត់គេចចេញត្រូវជួបឈ្មោះ យ សយ ដោយមានកាន់ដំបងឈើនៅនឹងដៃ វាយមកលើ គ ត ចំក្បាលបណ្ដាលឱ្យបែកក្បាលចេញឈាម តែ គ ត មិនដួលទេហើយបានរត់ទៅផ្ទះ ពេលដល់ផ្ទះដោយមានកំហឹងជាមួយនិងឈ្មោះ ន ច និង យ សយ នោះក៏យកកាំបិតផ្គាក់មករកកាប់អ្នកទាំង ០២ ពេលរត់មកដល់របងការ៉ាសសាំងបេត្រូណាស់ជួប និងឈ្មោះ ន ច និង យ សយ ហើយឈ្មោះ យ សយ ចាប់កាំបិតពីឈ្មោះ គ ត ជាប់ ឈ្មោះ ន ច មកវាយ ត ឯ យ សយ ក៏វាយដែរ រហូតដល់ឈ្មោះ ត ដួលទៅនឹងដីរហូតដល់សន្លប់ ហើយត្រូវប្រជាពលរដ្ឋនៅក្បែរនោះឃើញមកឃាត់បំបែកចេញ ដោយក្រុមគ្រួសាររបស់ ត ដឹក ត មកព្យាបាលរបួសនៅពេទ្យ ។ ចំពោះជនល្មើសឈ្មោះ យ សយ ត្រូវសមត្ថកិច្ចប៉ូលីសឃាត់ខ្លួន ឯឈ្មោះ ន ច បានរត់គេចខ្លួនបាត់រហូតដល់សព្វថ្ងៃ ឈ្មោះ យ សយ ពេលបញ្ជូនខ្លួនមកដល់តុលាការដោយមានអ្នកធានាត្រឹមត្រូវ តុលាការបានអនុញ្ញាតនៅខាងក្រៅឃុំ ។

## នាពេលសវនាការ

-ក្រឡាបញ្ជីបានអានដីកាចាប់ខ្លួនលើឈ្មោះ ន ច ហៅ ប្ដីយាយ អម ភេទប្រុស អាយុ ៣២ឆ្នាំ លេខ ៨៥ ដច.០៣ ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៣ របស់ចៅក្រមស៊ើបអង្កេត នៃតុលាការក្រុងព្រះសីហនុ ។

-ឈ្មោះ យ សយ ជាជនជាប់ចោទបានឆ្លើយថា កាលពីថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០២ វេលាម៉ោង ០៨ និង ៣០នាទីយប់ ខ្លួនរៀបចំហូបបាយ ខ្លួនបានឮអ្នកជួលផ្ទះខ្លួនស្រែកប្រាប់ខ្លួនថា មានគេដេញកាប់គ្នា គឺដេញកាប់អ្នកជួលផ្ទះខ្លួន ហើយខ្លួនក៏ចេញទៅមើលក៏ឃើញឈ្មោះ ខ កំពុងតែកាប់ទ្វារផ្ទះដែលឈ្មោះ ច ជួល ខ្លួនមកឃើញមានឈាមនៅក្បាលហូរប្រឡាក់អាវរបស់ជនរងគ្រោះឈ្មោះ ខ រួចទៅហើយ ហើយខ្លួនក៏ស្រែកឱ្យទៅឈ្មោះ ខ ថាម្ដេចឯងកាប់ផ្ទះជួលរបស់អញទៅវិញ ពេលនោះឈ្មោះ ខ បានងាកមកកាប់ខ្លួនវិញ ខ្លួនក៏ចាប់កាំបិតកាប់ ហើយបានមុតចង្អុលដៃឆ្វេងទៀតផង ឃើញមុតដូច្នេះខ្លួនក៏រុញឈ្មោះ ខ ឱ្យដួលទៅលើដីជិតរបងការ៉ាសសាំងបេត្រូណាស់ (PITRONAS ) ពេលនោះក្រុមគ្រួសាររបស់ឈ្មោះ ខ ចេញមកឃើញចោទថា ខ្លួនបានកាប់ឈ្មោះ ខ នោះ ពេលនោះខ្លួនក៏បានឃើញក្រុមគ្រួសាររបស់ឈ្មោះ ខ បានដឹកឈ្មោះ ខ ទៅពេទ្យបាត់ទៅ ឯកាំបិតខ្លួនជាអ្នកបានដកទុកពីឈ្មោះ ខ ដើម្បីរក្សាទុកជាភស្តុតាង ខ្លួនក៏ឱ្យបងប្អូនទៅប្ដឹងប៉ូលីស ប៉ូលីសក៏ហៅខ្លួនទៅសួរនាំ ហើយក៏ឃាត់ខ្លួនអស់រយៈពេល០២យប់ដែរ ចំពោះបញ្ហានេះខ្លួនមិនបានបង្ករបួសអ្វីជាមួយឈ្មោះ ខ ទេ ព្រោះពេលនោះមានសាក្សី គេឃើញគ្រប់១គ្នា ។ក្រោយពេលកើតហេតុឈ្មោះ ច បានរត់គេចខ្លួនបាត់ ឯប្រពន្ធកូនរបស់ ច បានរើតវ៉ាន់ចេញពីផ្ទះជួលអស់ទៅទៀត ប្រវត្តិរូបឈ្មោះ ច ខ្លួនមិនស្គាល់ច្បាស់ទេ ។ ដល់ប៉ូលីសចាប់ឈ្មោះ ច មិនបានបែរជាមកឃាត់ខ្លួនទៅវិញ ហេតុនេះសូមឱ្យតុលាការ

រកយុត្តិធម៌ឱ្យខ្លួនផង បើខ្លួនវាយឈ្មោះ ១ នោះ គឺពិតជាងាប់បាត់ទៅឈ្មោះ ១ នោះបើមើលមាឌ គឺខុសគ្នាឆ្ងាយណាស់ ខ្លួនមានមាឌធំ ឯឈ្មោះ ១ មាឌតូច កាំបិតចាប់បានខ្លួនមិនកាប់តបតទៅវិញផង ។

-ឈ្មោះ គ.ឥ៖ ហៅ ១ ជាជនរងគ្រោះបានឆ្លើយថា កាលពីថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០២ វេលាម៉ោងប្រហែល ៨:០០ជាងយប់ ខ្លួនកំពុងតែអង្គុយមើលទូរទស្សន៍ជាមួយម្តាយខ្លួនក្នុងផ្ទះក៏រលត់ភ្លើង ខ្លួនក៏ចេញទៅដោយយកឈើតូចមួយ និង ដែកកេះទៅកន្លែងឌីស៊ុងទ័រភ្លើង ក៏កេះដែកកេះមើលក៏ឃើញឌីស៊ុងទ័រធ្លាក់ចុះ ក៏បំរុងយកឈើទៅឆ្កិះឡើងលើ ដើម្បីឱ្យភ្លើងអគ្គិសនីឆេះនៅផ្ទះខ្លួន ស្រាប់តែឈ្មោះ ច ដែលជាអ្នកជួលផ្ទះឈ្មោះ ឃ បានដកខ្សែក្រវ៉ាត់មកវាយខ្លួនចំនួន ០៣ខ្សែក្រវ៉ាត់ចំក ពេលនោះខ្លួនក៏រត់ តែត្រូវឈ្មោះ រ និង ឈ្មោះ ឃ សខ បានចាប់ខ្លួនជាប់ព្រមទាំងវាយ និង ធាក់ទៀត និង ស្របពេលនោះឈ្មោះ ឃ សឃ បានយកឈើបួនជ្រុងប៉ុនកដៃប្រវែងកន្លះម៉ែត្រមកវាយត្រូវក្បាល ០១ដំបងចេញឈាម ខ្លួនក៏រត់ទៅផ្ទះដោយខឹងខ្លាំងពេក ខ្លួនក៏យកកាំបិតផ្គាក់មករកកាប់អ្នកទាំង ០៤នាក់ ពេលត្រឡប់មកវិញក៏ឃើញ ០៤នាក់ នៅក្បែររបងការ៉ាសសាំងបេត្រូណាស់ ខ្លួនក៏ដើរចូលទៅស្រាប់តែឈ្មោះ ឃ សខ ចាប់កាំបិតជាប់ ហើយគេព្រួតវាយខ្លួនរហូតដល់សន្លប់ ។ ពេលដឹងខ្លួនឡើងខ្លួនក៏នៅសំរាកព្យាបាលនៅមន្ទីរពេទ្យ ។

-ឈ្មោះ គ សរ ជាដើមបណ្តឹងរដ្ឋប្បវេណី បានឆ្លើយថា មុនថ្ងៃកើតហេតុ កូនខ្លួនកំពុងតែមើលទូរទស្សន៍ស្រាប់តែពេលនោះភ្លើងអគ្គិសនីត្រូវដាច់ កូនខ្លួនក៏ដើរទៅមើលមួយសន្ទុះក៏ត្រឡប់មកវិញ ឃើញមានឈាមប្រឡាក់មុខ និង អាវនៅក ខ្លួនពេលនោះខ្លួនក៏សួរវា ក៏វាមិនឆ្លើយនិងខ្លួនដែរ ក៏ឃើញវាទាញយកកាំបិតផ្គាក់ ០១ ចេញពីផ្ទះដើម្បីទៅកាប់គេវិញ ខ្លួនក៏រត់តាមក្រោយ តែទៅតាមវាមិនទាន់ ខ្លួនក៏ពឹងអ្នកជិតខាងឱ្យជួយទូរស័ព្ទហៅប្តីខ្លួនមកជួយក្រោយពេលទូរស័ព្ទរួចហើយខ្លួនក៏រត់ទៅតាម ពេលជិតដល់ការ៉ាសសាំងបេត្រូណាស់ ខ្លួនឃើញកូនខ្លួនសន្លប់បាត់ ទៅហើយមានឈាមពេញក្បាលពេញខ្លួន ខ្លួនក៏យកកូនទៅមន្ទីរពេទ្យចំការចេក នៅពេលវាដឹងខ្លួន វាប្រាប់ថា អ្នកវាយវាមានឈ្មោះ ខ ឈ្មោះ ឃ ឈ្មោះ រ និងម្នាក់ទៀតមិនស្គាល់ឈ្មោះ ។ ចំពោះបញ្ហានេះ ខ្លួនសុំឱ្យតុលាការផ្តន្ទាទោសតាមច្បាប់ និង ទាមទារសំណងព្យាបាលរបួស និង ជម្ងឺចិត្តជាទឹកប្រាក់ចំនួន ៧០០ដុល្លា ។

-តាមការអានចម្លើយរបស់ឈ្មោះ ឃ គន ហៅ ៖ ជាសាក្សី ឆ្លើយថា កាលពីថ្ងៃខែមិនចាំ ឆ្នាំ ២០០២ វេលាម៉ោងប្រហែលជិត ៨:០០យប់ ខ្លួនកំពុងតែអង្គុយរៀននៅលើផ្ទះ ខ្លួនក៏ឮសូរសម្លេងគេឈ្លោះគ្នានៅកន្លែងបង្គោលភ្លើងនៅខាងផ្ទះខ្លួន ហើយអ្នកឈ្លោះគ្នានោះ គឺឈ្មោះ ច ដែលហៅថា ប្តីយាយ អប ជាមួយជនរងគ្រោះឈ្មោះ ១ (ឥ៖) ពេលនោះខ្លួនមិនបានទៅមើលឡើយ ឈ្មោះ ច ពីមុនជួលផ្ទះម្តាយខ្លួនស្នាក់នៅ ឥឡូវនេះមិនដឹងជាទៅរស់នៅឯណាទេ តាំងពីថ្ងៃកើតហេតុនោះមក បានប្រហែល ១០នាទី ក្រោយមក ឈ្មោះ ច ឈ្លោះគ្នាជាមួយឈ្មោះ ១ ម្តងទៀត ដោយឃើញឈ្មោះ ១ មកកាន់កាំបិតផ្គាក់ទៀតផង ខ្លួនក៏ចុះពីលើផ្ទះក៏ឃើញឈ្មោះ ១ កំពុងតែកាប់ទ្វារផ្ទះម្តាយខ្លួនបានជួលឱ្យ ឈ្មោះ ច ឃើញដូច្នេះ ខ្លួនក៏រត់ទៅប្រាប់បងខ្លួនឈ្មោះ ឃ សខ. ឈ្មោះ ឃ ឮក៏មកជាមួយ ពេលបងប្អូនទាំងបីមកដល់កន្លែងកើតហេតុ ក៏ឃើញឈ្មោះ ១ ដួលសន្លប់នៅក្បែររបងការ៉ាសសាំងរួចទៅហើយបងប្រុសខ្លួនឈ្មោះ ឃ ក៏រើសយកកាំបិតផ្គាក់ ដែលនៅក្បែរខ្លួនឈ្មោះ ១ មកកាន់ទុកជាភស្តុតាងស្របពេលនោះឈ្មោះ ស ជាឪពុកក្មេកជនរងគ្រោះមកដល់ ស្រែកថា បងប្អូនខ្លួនទាំងបីជាឃាតករពេលនោះក្រុមគ្រួសារជនរងគ្រោះមកកាន់តែច្រើន និង មានអ្នកភូមិជាច្រើនទៀត បងប្អូនខ្លួនក៏នាំគ្នាទៅផ្ទះបងប្អូនខ្លួនមិនមានការពាក់ព័ន្ធជាមួយឈ្មោះ ១ នោះទេ មានតែឈ្មោះ ច ទេ ដែលបានឈ្លោះ និង វាយគ្នាជាមួយឈ្មោះ ១ នោះ ឯឈ្មោះ ១ ដួលសន្លប់នោះ គឺខ្លួនមិនបានដឹងទេ ។

-តាមការអានចម្លើយឈ្មោះ ឃ សខ ជាសាក្សីឆ្លើយថា នៅថ្ងៃខែមិនចាំ ឆ្នាំ ២០០២ វេលាម៉ោងប្រហែលជា ០៨ និង ៣០នាទី ខ្លួនកំពុងតែមើលទូរទស្សន៍ ស្រាប់ឮសម្លេងប្អូនប្រុសឈ្មោះ ៖ ស្រែកហៅខ្លួនថា មានគេវាយគ្នានៅផ្ទះជួល គឺឈ្មោះ ឃ ហៅប្ដីយាយ អប ឈ្លោះគ្នាជាមួយឈ្មោះ ទ ពេលនោះខ្លួនក៏ដើរមកមើល ពេលមកដល់កន្លែងកើតហេតុគេចប់ទៅហើយ ឯជនរងគ្រោះខ្លួនមិនបានដឹងទេ ខ្លួនក៏ត្រឡប់មកផ្ទះវិញ ដោយឮក្រុមគ្រួសារជនរងគ្រោះមកគ្នាច្រើន ហើយចោទថា ខ្លួនជាឃាតករទៀតផង ។

-តាមការអានចម្លើយឈ្មោះ អ ស ជាសាក្សីជនរងគ្រោះឆ្លើយថា នៅថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០២ វេលាម៉ោង ០៨ និង ៣០នាទីយប់ ខ្លួនកំពុងតែសំរាកនៅក្នុងផ្ទះ ក៏ឮមនុស្សស្រែកយំនៅខាងក្រោយផ្ទះខ្លួន ខ្លួនក៏បើកទ្វារចេញមើល ក៏ឃើញប្រពន្ធជនរងគ្រោះស្រែកទ្រហោយំ ដោយមានប្រឡាក់ឈាមខោអាវទៀតផង ពេលនោះខ្លួនសួរប្រពន្ធជនរងគ្រោះ គាត់ថា គេកាប់បង ទ ហើយ ខ្លួនសួរអា ទ ទៅឯណាហើយ ប្រពន្ធ ទ ថា ត្រឡប់ក្រោយវិញហើយ ខ្លួនក៏ដើរមកផ្ទះវិញ ស្រាប់តែឮសម្លេងមួយផ្លូង ពេលនោះខ្លួនក៏បានឃើញឈ្មោះ ខ និងឈ្មោះ. ៖ ឈរនៅមុខផ្ទះខ្លួនសួរទៅអ្នកទាំងពីរ ឈ្មោះ ខ ឆ្លើយថា នោះវាងាប់ហើយយកទៅ ហើយឈ្មោះ ៖ ក៏និយាយទៀតថា រឿងប៉ុណ្ណឹង១ចាំបាច់វាយឱ្យគេងាប់ ខ្លួនក៏បានទៅរកជនរងគ្រោះ ព្រោះពេលនោះងងឹតពេក ខ្លួនក៏ស្ទាបរកទៅឃើញជនរងគ្រោះដេកសន្លប់នៅមុខផ្ទះខ្លួន ដោយមានឈើមូលនៅមានសល់ថ្នាំងមានមុខ ១តឹកកន្លះ បណ្ដោយប្រវែង ០៦សមនៅលើខ្លួនអ្នករងគ្រោះ ពេលនោះប្រពន្ធជនរងគ្រោះ និង អ្នកជិតខាងមកច្រើនកុះករក៏បានលើកជនរងគ្រោះមកខាងក្នុងផ្ទះខ្លួន ហើយខ្លួនក៏ដើរចេញមកក្រៅរបង ក៏ឃើញឈ្មោះ ខ កាន់កាំបិតផ្គាក់ ១. ឈ្មោះ ៖ ក៏នៅទីនោះដែរ ខ្លួនក៏បានសួរគេមិនឆ្លើយហើយគេរត់ទៅបាត់អស់ទៅ ។ ខ្លួនក៏បានយកឡានដឹកជនរងគ្រោះទៅ មន្ទីរពេទ្យចំការចេកបានរយៈពេល ១៥ នាទី ជនរងគ្រោះដឹងខ្លួន ឯរឿងរ៉ាវអ្វីផ្សេងទៀតខ្លួនមិនបានដឹងឡើយ ។

-តាមអានចម្លើយរបស់ឈ្មោះ អ ឌណ ជាសាក្សីឆ្លើយថា កាលពីយប់ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០២ ប្រហែលម៉ោង ០៨ជាង ខ្លួន និង ប្ដីខ្លួនឈ្មោះ ទ បាននៅក្រោមផ្ទះភ្លើងដាច់ ពេលនោះប្ដីខ្លួនដើរទៅមើលឪស្សង់ទ័រ ដោយចាំប្ដីខ្លួនយូរពេក ខ្លួនក៏ទៅតាមមើល ពេលដល់កាប៊ិនភ្លើង ខ្លួនក៏បានឃើញប្ដីយាយ អប ឈ្មោះ ខ. ឈ្មោះ ឃ និង ឈ្មោះ ៖ បានព្រួតគ្នាវាយប្ដីខ្លួន ទោះបីខ្លួនស្រែកឃាត់យ៉ាងណាក៏ដោយ ដោយគេនៅតែព្រួតវាយប្ដីខ្លួនដដែល ហើយប្ដីយាយ អប បានយកខ្សែក្រវ៉ាត់វាយប្ដីខ្លួនទៀតផង ឈ្មោះ ឃ មានកាន់ដំបងបួនជ្រុងវាយប្ដីខ្លួន ពេលនោះខ្លួនក៏ស្ទុះទៅអោបប្ដីខ្លួន ដោយប្រឡាក់សុទ្ធតែឈាម ហើយខ្លួនក៏ស្រែកឱ្យគេជួយ ពេលនោះប្ដីខ្លួនក៏រត់ទៅផ្ទះខ្លួនក៏រត់ទៅតាមក្រោយពេលដល់ផ្ទះ ប្ដីខ្លួនត្រឡប់មកវិញ ដោយមានកាន់កាំបិតផ្គាក់រត់ទៅវិញ ខ្លួនក៏បានឃាត់តែគាត់មិនស្ដាប់ឡើយ ខ្លួនក៏រត់តាមក្រោយគាត់ ពេលដល់កាប៊ិនភ្លើងខ្លួនក៏ឈរនៅពីក្រោយប្ដីខ្លួន ខ្លួនឃើញប្អូននាក់ ដែលឈ្លោះគ្នាជាមួយប្ដីខ្លួន ប្ដីខ្លួនក៏ស្ទុះទៅរកពួកវា ហើយមានការប្រតាយប្រតប់គ្នា ឈ្មោះ ឃ និង ឈ្មោះ ខ ជាអ្នកវាយប្ដីខ្លួនដោយផ្ទាល់ដោយមានយកដុំថ្មគប់ប្ដីខ្លួនទៀតផង ខ្លួនក៏បានស្រែក ឪពុកខ្លួនឈ្មោះ ស ឱ្យជួយក៏ឃើញមកដល់កន្លែងកើតហេតុឈ្មោះ ខ ស្រែកថា ប្ដីខ្លួនងាប់ហើយ ព្រោះងងឹតពេក ខ្លួនក៏រាវរកប្ដីខ្លួន គាត់សន្លប់បាត់ស្មារតីក៏បានបញ្ជូនទៅមន្ទីរពេទ្យចំការចេកបាន ១៥នាទី ទើបដឹងខ្លួន ។

-ឃើញបានលិខិតកោសល្យវិច្ច័យរបស់មន្ទីរពេទ្យបង្អែកក្រុងព្រះសីហនុ បញ្ជាក់ពីទំហំមុខរបួស និង ការសន្និដ្ឋានរបួសរបស់ជនរងគ្រោះ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៣ ។

-បានឃើញកំណត់ហេតុទទួលវត្ថុតាងរបស់តំណាងអយ្យការអមតុលាការក្រុងព្រះសីហនុ ដែលទទួលពីនគរបាលក្រុងព្រះសីហនុ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២ រួមមានកាំបិតផ្គាក់មានដងចំនួនមួយ និង កំណាត់មែកឈើចំនួនមួយ ។

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានមានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ន ម ពីបទបង្ករបួសដោយចេតនាប្រព្រឹត្តនៅភូមិ ៣ សង្កាត់ ២ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្ដន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ហេតុនេះសុំឱ្យតុលាការជំនុំជំរះទៅតាមច្បាប់ ដោយឡែកឈ្មោះ យ សយ ដែលពីមុនលោកព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់ដែរនោះក៏សុំឱ្យតុលាការពិនិត្យពិចារណាទៅតាមច្បាប់ដែរ ដោយអនុគ្រោះ ។

-ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើប្រវត្តិរូបជនជាប់ចោទ

-ក្រោយពីបានស្ដាប់ចម្លើយជនរងគ្រោះ

-ក្រោយពីបានស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់ចម្លើយសាក្សី និង ការអានចម្លើយសាក្សី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

## តុលាការក្រុងព្រះសីហនុ

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា

-កាលពីយប់ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០២ ពេលដែលឈ្មោះ គ ត កំពុងយកកូនឈើផ្គិះឱ្យស្បង់ទ័រភ្លើងកន្លែងកង់ទ័ររបស់ខ្លួនដែលវាលោត ស្រាប់តែពេលនោះឈ្មោះ ន ម ហូតខ្សែក្រវ៉ាត់ពីចង្កេះខោរបស់ខ្លួនវាយខាងក្បាលខ្សែក្រវ៉ាត់ទៅលើឈ្មោះ គ ត ជាច្រើនខ្សែក្រវ៉ាត់បណ្ដាលឱ្យ គ ត មានការឈឺចុកចាប់ស្ទុះរត់មកផ្ទះយកកាំបិតផ្គាក់ទៅកាប់ឈ្មោះ ន ម ទៅដល់របងការ៉ាសសាំងបេត្រូលាស់ ក៏ឈ្មោះ យ សយ ចាប់យកកាំបិតចេញ និង ន ម បានវាយ គ ត រហូតដល់ដួលសន្លប់នៅនឹងដី ហើយត្រូវអ្នកជិតខាងឃើញឃាត់ចាប់បំបែកចេញ ។ គ ត ត្រូវក្រុមគ្រួសារយកមកព្យាបាលនៅមន្ទីរពេទ្យចំការចេក ក្រុងព្រះសីហនុ ដោយឡែកឈ្មោះ យ សយ ត្រូវសមត្ថកិច្ចធ្វើការឃាត់ខ្លួន ឯឈ្មោះ ន ម រត់គេចខ្លួនបាត់ ។ ឈ្មោះ យ សយ ពេលបញ្ជូនមកតុលាការ ដោយមានអ្នកធានាក៏ត្រូវឱ្យនៅក្រៅឃុំជាបណ្ដោះអាសន្ន ។

-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ ន ម ជាអំពើប្រព្រឹត្តដោយចេតនា ដោយជនជាប់ចោទឈ្មោះ ន ម បានប្រើប្រាស់ខ្សែក្រវ៉ាត់វាយទៅលើជនរងគ្រោះរហូតដល់ដួលសន្លប់បាត់ស្មារតី ហើយអំពើនេះបំពានលើមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ជនជាប់ចោទឈ្មោះ ន ម ជានីតិជនមានស្មារតីគ្រប់គ្រាន់ មានកំលាំងបរិបូរណ៍ ប្រព្រឹត្តបទល្មើសដោយដឹងខុសត្រូវ ហើយអំពើនេះធ្វើឱ្យខូចរបៀបរៀបរយសាធារណៈ បាត់សណ្ដាប់ធ្នាប់សង្គម និង ប៉ះពាល់ដល់សុខភាពរបស់ប្រជាពលរដ្ឋ ដែលច្បាប់កំពុងការពារយ៉ាងតឹងរ៉ឹងបំផុត ។

-តាមចម្លើយសាក្សីឈ្មោះ អ ផណ បានបញ្ជាក់ថា ខ្លួនពិតជានៅកន្លែងកើតហេតុ ខ្លួនបានឃើញឈ្មោះ ន ម ប្រើប្រាស់ខ្សែក្រវ៉ាត់ទៅលើ គ ត រហូតដល់សន្លប់ ដោយផ្ទាល់ និង ភ្នែក ចម្លើយនេះអាចឱ្យតុលាការជឿបាន ។

-តាមចម្លើយសាក្សីឈ្មោះ យ សខ និង យ គឧ បានបញ្ជាក់ថា ខ្លួនបានឮប្រជាជនរស់ក្បែរផ្ទះខ្លួនស្រែកថា ឈ្មោះ ន ម និងឈ្មោះ គ ត វាយគ្នា ខ្លួនរត់ទៅមើលឃើញឈ្មោះ គ ត ដួលសន្លប់ហើយ ហើយបានឃើញ

**ន ឃ** រត់គេចខ្លួន ដោយឡែកឈ្មោះ **យ សយ** បានរត់មកមើលជំណាលនឹងខ្លួនដែរ ចម្លើយនេះអាចឱ្យតុលាការជឿបាន ។

-តាមលទ្ធផលកោសល្យវិច្ច័យរបស់មន្ទីរពេទ្យបង្អែកក្រុងព្រះសីហនុ បានបញ្ជាក់ថា ជនរងគ្រោះត្រូវរបួស : ទី១ របួសក្បាលខាងក្រោយរាងទ្រវែងចុះក្រោមបណ្តោយ ០២សម ទទឹង ០.៥សម ជំរៅ ០.៥ សម . ទី២ របួសចុងភ្អែកឆ្វេងរាងទ្រវែងនៅស្របគ្របកភ្អែកលើប្រវែងបណ្តោយ ០១សម ទទឹង ០.៣ សម និង ជំរៅ ០.៥សម ហើយមុខរបួសទាំងនេះអាចនឹងជាសះស្បើយក្នុងរយៈពេល ០២សប្តាហ៍ គប្បីតុលាការពិចារណាលើបញ្ហានេះ ។

-តាមការពិនិត្យលើប្រវត្តិរូបជនជាប់ចោទឈ្មោះ **ន ឃ** ក៏បានគេចខ្លួន ក្រោយពេលប្រព្រឹត្តរួចហើយ ហើយឈ្មោះនេះត្រូវបានតុលាការចេញដីកាចាប់ខ្លួនរួចហើយដែរ ។

-ក្នុងពេលសវនាការអ្នកស្រី **គ សរ** ត្រូវជាម្តាយបង្កើតរបស់ជនរងគ្រោះ និង ជាដើមបណ្តឹងរដ្ឋប្បវេណី បានប្តឹងទាមទារសំណងថ្លៃថ្នាំពេទ្យ ថ្លៃព្យាបាលរបួស និង ជម្ងឺចិត្តពីជនល្មើសឈ្មោះ **ន ឃ** និង **យ សយ** ជាប្រាក់ចំនួន ៧០០ USD មានលក្ខណៈសមស្រប គប្បីតុលាការពិចារណាលើបញ្ហានេះ ។

-ជនរងគ្រោះក៏បានដឹងដែរថា ខ្លួនយកកាំបិតទៅនេះ គឺគោលបំណងសម្លាប់គេ ឬធ្វើឱ្យគេរបួសដូចខ្លួនដែរ តែនេះជាសំណាងល្អ បើកុំបាន **យ សយ** បានចាប់កាំបិតចេញបាន នោះមិនដឹងជនរងគ្រោះកាប់ត្រូវឈ្មោះ **ន ឃ** យ៉ាងណានោះទេ ឬក៏ត្រូវកាប់អ្នកផ្សេងទៀត ព្រោះកន្លងមកក្រុមគ្រួសាររបស់ឈ្មោះ **គ តរ** ធ្លាប់មានទំនាស់ជាមួយរឿងផ្លូវដើរជាមួយក្រុមគ្រួសាររបស់ **យ សយ** ។

-ជនរងគ្រោះខ្លួនឯងក៏ដឹងច្បាស់ដែរថា ខ្លួនពិតជាបានកាប់ទ្វារផ្ទះរបស់ឈ្មោះ **ន ឃ** ដែលបានជួលពីម្តាយរបស់ **យ សយ** ការកាប់នេះ គឺដើម្បីឱ្យឈ្មោះ **ន ឃ** ចេញពីក្នុងផ្ទះ តែគេមិនចេញក៏កាប់មាត់ទ្វារទៅនេះសរបញ្ជាក់ឱ្យឃើញថា ខ្លួនឯងក៏មានកំហុសផងដែរ ។

-មានពិរុទ្ធភាពលើឈ្មោះ **ន ឃ** ពីបទបង្ករបួសដោយចេតនា ប្រព្រឹត្តនៅភូមិ ៣ សង្កាត់ ២ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ឈ្មោះ **យ សយ** ពិតមែនតែនៅកន្លែងកើតហេតុ ហើយបានចាប់យកកាំបិតពី **គ តរ** តែដោយសារខ្លួនមានកាន់កាំបិត ដែលជារបស់ **គ តរ** នោះមានអ្នកជិតខាងឃើញ និង ក្រុមគ្រួសារជនរងគ្រោះចោទថា ជាឃាតករ សមត្ថកិច្ចក៏បានចាប់ខ្លួនឈ្មោះ **យ សយ** ទៅ តែអ្នកបានប្រព្រឹត្តផ្ទាល់ គឺឈ្មោះ **ន ឃ** ជាមួយឈ្មោះ **គ តរ** ការឈ្លោះគ្នាមានចំនួន ០២លើក បើតាមការបញ្ជាក់របស់សាក្សី ចំពោះបញ្ហាឈ្មោះ **យ សយ** នេះ តុលាការគិតគួរពិចារណាដល់បញ្ហានេះ ។

-ចម្លើយសាក្សីមានមូលដ្ឋានគ្រប់គ្រាន់គួរឱ្យតុលាការជឿបាន ។

## ហេតុដូច្នេះតុលាការក្រុងព្រះសីហនុ

## សំរេច :

**ផ្តន្ទាទោស :**

១-ឱ្យឈ្មោះ **យ សយ** រួចផុតពីបទចោទប្រកាន់របស់តំណាងអយ្យការ ដែលបានចោទប្រកាន់ តាមដីកាសន្និដ្ឋានស្ថាពរលេខ ៤៤៦ ដសព ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៣ ចាប់តាំងពីថ្ងៃនេះតទៅ ។

២-ឈ្មោះ **ន ឃ** ហៅ ប្តីយាយ **អប** អាយុ ៣២ឆ្នាំ ភេទប្រុស ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០១ឆ្នាំ

( មួយឆ្នាំ ) គិតពីចាប់ខ្លួនបាន និង យកឃុំខ្លួននៅពន្ធនាគារក្រុងព្រះសីហនុ ក្រោយពេលសាលក្រមនេះ ចូលជាស្ថាពរ ។

ពីបទបង្ករបួសដោយចេតនា ប្រព្រឹត្តនៅភូមិ ៣ សង្កាត់ ២ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និង ឱ្យផ្ដន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៣-ឱ្យឈ្មោះ **ន ចា** ហៅ ប៉ូយាយ **អច** សងសំណងថ្លៃថ្នាំព្យាបាលរបួស និង ជម្ងឺចិត្តជាទឹកប្រាក់ចំនួន ២.៨០០.០០០៛០០ (ពីរលានប្រាំបីរយពាន់រៀលគត់) ទៅអ្នកស្រី **គ សរ** ជាដើមបណ្ដឹង ចាប់តាំងពីថ្ងៃ សាលក្រមនេះ ចូលជាស្ថាពរ ។

ក្នុងករណីទណ្ឌិតគ្មានប្រាក់សងធនទណ្ឌទេ ត្រូវដាក់គុកបង្ខំដល់រូបកាយ តាមមាត្រា ៧ នៃច្បាប់ស្ដីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

៤-វត្ថុតាងរួមមានកាំបិតផ្គាក់មានដងចំនួន ០១ និង កំណាត់មែកខ្នុរ ០១ ត្រូវរឹបអូស និង បំផ្លាញចោល ។

សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈនៅចំពោះមុខជនជាប់ចោទឈ្មោះ **យ សយ** ជនរងគ្រោះ ដើមបណ្ដឹង និង កំបាំងមុខជនជាប់ចោទឈ្មោះ **ន ចា** បើកផ្លូវប្ដឹងទាស់ និង ឧទ្ធរណ៍ក្នុងកំឡុងច្បាប់ ។

**ក្រឡាបញ្ជី**

[redacted]

**ចៅក្រមជំនុំជំរះ**

[redacted]